**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១០២ សសរ**

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារហិរញ្ញវត្ថុបៃតង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារហិរញ្ញវត្ថុបៃតង ដែលសរសេរជាអក្សរកាត់ថា **ក.ហ.ប.** ដើម្បីចូលរួមរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងវិធានការកៀរគរហិរញ្ញវត្ថុបៃតងសម្រាប់គាំទ្រដល់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

- តំណាងធនាគារជាតិនៃកម្ពុជា ១រូប ប្រធាន
- តំណាងក្រសួងបរិស្ថាន ១រូប អនុប្រធាន

- តំណាងធនាគារជាតិនៃកម្ពុជា ១រូប អនុប្រធានប្រចាំការ
- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី ១រូប សមាជិក
- តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ១រូប សមាជិក
- តំណាងក្រសួងរ៉ែនិងថាមពល ១រូប សមាជិក
- តំណាងក្រសួងពាណិជ្ជកម្ម ១រូប សមាជិក
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប សមាជិក
- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប សមាជិក
- តំណាងក្រសួងផែនការ ១រូប សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប សមាជិក
- តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន ១រូប សមាជិក
- តំណាងនិយ័តករមូលបត្រកម្ពុជា ១រូប សមាជិក
- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១រូប សមាជិក
- តំណាងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ១រូប សមាជិក។

**គ.ហ.ប**. អាចមានសមាសភាពបន្ថែមជាអនុប្រធាននិងសមាជិកតាមការចាំបាច់។ សមាសភាពបន្ថែមនេះ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

សមាសភាពជាក់ស្ដែងរបស់ **គ.ហ.ប**. ត្រូវទទួលស្គាល់ដោយសេចក្ដីសម្រេចរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា បន្ទាប់ពីទទួលបានការចាត់តាំងពីរដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នសាមី។

**ប្រការ២ ._**

**គ.ហ.ប**. មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ដឹកនាំនិងសម្របសម្រួល ការរៀបចំ និងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងទិសដៅការងារអាទិភាពសម្រាប់ការអភិវឌ្ឍនិងការកៀរគរហិរញ្ញវត្ថុបៃតងនៅកម្ពុជា
- ជំរុញនិងគាំទ្រការរៀបចំយន្តការគាំទ្រនិងក្របខ័ណ្ឌពាក់ព័ន្ធ ដើម្បីអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសម្រាប់ហិរញ្ញវត្ថុបៃតង
- ជំរុញការសិក្សាស្រាវជ្រាវ ការបណ្ដុះបណ្ដាល និងការផ្សព្វផ្សាយចំណេះដឹងពាក់ព័ន្ធនឹងហិរញ្ញវត្ថុបៃតងស្របតាមនិន្នាការអភិវឌ្ឍថ្មីៗ
- សម្របសម្រួលនិងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនិងដៃគូអភិវឌ្ឍក្នុងការជំរុញការអភិវឌ្ឍហិរញ្ញវត្ថុបៃតងនៅកម្ពុជា
- ជំរុញនិងគាំទ្រការអភិវឌ្ឍគម្រោងនិងឧបករណ៍ហិរញ្ញវត្ថុបៃតងដើម្បីគាំទ្រការអភិវឌ្ឍប្រកបដោយចីរភាព
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៣ ._**

**គ.ហ.ប**. មានក្រុមការងារបច្ចេកទេសហិរញ្ញវត្ថុបៃតង ដែលសរសេរជាអក្សរកាត់ថា **គ.ប.ហ.ប**. ជាសេនាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ **គ.ប.ហ.ប**. ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា។



ទ

**ប្រការ៤ ._**

អនុប្រធាននិងសមាជិកនៃ **គ.ហ.ប**. ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធានឬអាចចាត់តាំងតំណាងដើម្បីចូលរួមប្រជុំជំនួស។ ក្នុងករណីប្រធានអវត្តមាន ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ដឹកនាំកិច្ចប្រជុំជំនួស។

**ប្រការ៥ ._**

**គ.ហ.ប**. អាចអញ្ជើញឥស្សរជន តំណាងក្រសួង ស្ថាប័ន អង្គភាពផ្សេងៗ តំណាងពីវិស័យឯកជន ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ព្រមទាំងអ្នកជំនាញការជាតិនិងអន្តរជាតិចូលរួមប្រជុំនិងផ្តល់យោបល់តាមការចាំបាច់។

**ប្រការ៦ ._**

**គ.ហ.ប**. អាចបង្កើតក្រុមការងារចំពោះកិច្ចតាមការចាំបាច់ ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ហ.ប**.។

**ប្រការ៧ ._**

**គ.ហ.ប**. មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ធនាគារជាតិនៃកម្ពុជាដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ៨ ._**

ការចំណាយ មធ្យោបាយ និងសម្ភារៈបរិក្ខារសម្រាប់បំពេញការងាររបស់ប្រធាន អនុប្រធាន និងសមាជិក **គ.ហ.ប**. ជាបន្ទុករបស់ក្រសួង ស្ថាប័នសាមី។

**ប្រការ៩ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១កើត ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ